**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា**
**ប្រចាំអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា**
**នៅទីក្រុងហ្សឺណែវ**

សេចក្តីប្រកាសព័ត៌មាន

# កម្ពុជា គូសបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះសិទ្ធិមនុស្ស នៅក្នុងសម័យប្រជុំលើកទី៦២ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស

ទីក្រុងហ្សឺណែវ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៦ ព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់អះអាងសារជាថ្មី នូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ខ្លួន ចំពោះការលើកកម្ពស់ និងកិច្ចការពារសិទ្ធិមនុស្សតាមរយៈការចូលរួមយ៉ាងសកម្មរបស់ខ្លួន នាសម័យប្រជុំលើកទី៦២ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (HRC) ដែលបានប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២៦ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

ពេញសម័យប្រជុំនេះ ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា បានចូលរួមថ្លែងបទអន្តរាគមន៍ ចំនួន ២២ ដោយបានគូសបញ្ជាក់ពីវឌ្ឍនភាពជាបន្តបន្ទាប់របស់កម្ពុជា ក្នុងការជំរុញសិទ្ធិមនុស្ស និងការចូលរួមប្រកបដោយស្ថាបនារបស់ខ្លួន លើកិច្ចការជាច្រើន។ កម្ពុជា បានចូលរួមយ៉ាងសកម្ម ក្នុងកិច្ចសន្ទនាអន្តរកម្ម និងកិច្ចពិភាក្សានានា ដែលគ្របដណ្តប់លើសិទ្ធិសេដ្ឋកិច្ច សង្គម វប្បធម៌ ពលរដ្ឋ និងនយោបាយ សុខភាព និងការអប់រំ សមភាពយេនឌ័រ បម្រែបម្រួលអាកាសធាតុ ការធ្វើចំណាកស្រុក ការជួញដូរមនុស្ស ការទទួលបានយុត្តិធម៌ ការកាត់បន្ថយភាពក្រីក្រ សកម្មភាពមីនមនុស្សធម៌ ការប្រយុទ្ធប្រឆាំងនឹងការរើសអើងជាតិសាសន៍ កិច្ចសហប្រតិបត្តិការបច្ចេកទេស និងសាមគ្គីភាពអន្តរជាតិ។

កម្ពុជា ក៏បានលើកយកការវិវឌ្ឍថ្មីៗ លើបញ្ហាសិទ្ធិមនុស្ស តាមបណ្តោយព្រំដែនកម្ពុជា-ថៃ មកពិភាក្សាផងដែរ។ នៅក្នុងបទអន្តរាគមន៍ ក្រោមរបៀបវារៈទី២ និង៣ កម្ពុជា បានអំពាវនាវ ឱ្យមានការវិលត្រឡប់ដោយសុវត្ថិភាព ស្ម័គ្រចិត្ត និងថ្លៃថ្នូររបស់ជនភៀសខ្លួនផ្ទៃក្នុង កិច្ចការពារពលករចំណាកស្រុកពីការរើសអើង និងអំពើហិង្សា និងការគោរពច្បាប់មនុស្សធម៌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិពេញលេញ។ កម្ពុជា បានបញ្ជាក់អះអាងសារជាថ្មី នូវការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះការដោះស្រាយជម្លោះដោយសន្តិវិធី អនុលោមតាមធម្មនុញ្ញអង្គការសហប្រជាជាតិ និងច្បាប់អន្តរជាតិ។

ដោយបង្ហាញពីការគាំទ្រយ៉ាងមុតមាំរបស់ខ្លួន ចំពោះកិច្ចសហប្រតិបត្តិការពហុភាគី កម្ពុជា បានចូលរួម Co-sponsored សេចក្តីព្រាងសេចក្តីសម្រេចចិត្តចំនួន ០៤ ដែលស្នើដោយគុយបា ចិន ភូមិត និងបារាំង ស្តីពីបំណុលបរទេស និងសិទ្ធិទទួលបានសុខភាព កិច្ចសហប្រតិបត្តិការបច្ចេកទេស ស្តីពីបញ្ញាសិប្បនិម្មិតសម្រាប់ការចូលរួមចំណែក ការចូលរួមលើកិច្ចការមនុស្សធម៌ និងកិច្ចការពារបុគ្គលិកមនុស្សធម៌

អាសយដ្ឋាន៖ 3 Chemin Taverney, P.O. Box 213
1218 Grand-Saconnex, Geneva, Switzerland
ទូរស័ព្ទ៖ (៤១) ២២ [illegible]
អ៊ីមែល៖ camemb.gva@mfaic.gov.kh

ក្នុងជម្លោះប្រដាប់អាវុធ និងការលុបបំបាត់ការរើសអើងជាសកល ចំពោះការស្រលាញ់ភេទដូចគ្នា។ កម្ពុជា ក៏បានចូលរួមក្នុងសេចក្តីថ្លែងការណ៍រួម ចំនួន ១០ ដូចជាសេចក្តីថ្លែងការណ៍របស់ក្រុមអាស៊ីប៉ាស៊ីហ្វិក (APG) ស្តីពីការអប់រំ និងសុខភាព សេចក្តីថ្លែងការណ៍អាស៊ាន ស្តីពីផលប៉ះពាល់សិទ្ធិមនុស្សដោយសារបម្រែបម្រួលអាកាសធាតុ និងសេចក្តីថ្លែងការណ៍រួម ស្តីពីភាពក្រីក្រខ្លាំង កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការកសាងសមត្ថភាព សិទ្ធិស្ត្រី សិទ្ធិទទួលបានសុខភាព ការពង្រឹងដំណើរការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) និងស្ថានភាពនៅតំបន់មជ្ឈិមបូព៌ា។

កម្ពុជា ក៏បានបញ្ជាក់អះអាងសារជាថ្មី នូវការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះការចូលរួមប្រកបដោយស្ថាបនាជាមួយយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ រួមទាំងការបន្តកិច្ចសហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងកិច្ចសហការជាមួយអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

ការចូលរួមយ៉ាងសកម្មរបស់កម្ពុជា នាសម័យប្រជុំលើកទី៦២ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ខ្លួន ចំពោះកិច្ចសន្ទនាប្រកបដោយស្ថាបនា កិច្ចសហប្រតិបត្តិការពហុភាគី និងជម្រុញវឌ្ឍនភាពសិទ្ធិមនុស្ស។ កម្ពុជា នៅតែប្តេជ្ញាចិត្ត ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រុមប្រឹក្សាសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេស និងសហគមន៍អន្តរជាតិ ដើម្បីលើកកម្ពស់សន្តិភាព ការអភិវឌ្ឍប្រកបដោយចីរភាព និងការអនុវត្តសិទ្ធិមនុស្សយ៉ាងពេញលេញ សម្រាប់ទាំងអស់គ្នា។

---

អាសយដ្ឋាន៖ 3 Chemin Taverney, P.O. Box 213
1218 Grand-Saconnex, Geneva, Switzerland
ទូរស័ព្ទ៖ (៤១) ២២ ៧៨៨ ៧៧ ៧៣
អ៊ីមែល៖ camemb.gva@mfaic.gov.kh